# គំរោងគ្រប់គ្រងកាកសំណល់រាវ នៅខេត្តសាមុទប្រាកាន ប្រទេសថៃ

អត្ថបទកែសំរួល: ថ្ងៃទី ២៧ កុម្ភៈ ២០១០

ក្លងដែន (Klong Dan) មានទីតាំងស្ថិតនៅក្នុងខេត្តសាមុទប្រាកាន (Samut Prakarn) ប្រទេសថៃ មានចំងាយ ២០ គីឡូម៉ែត្រ ស្ថិតនៅជិតតំបន់ឧស្សាហកម្ម ភាគខាងកើតទីក្រុងបាងកក។ ក្លងដែន នៅរក្សាបានធនធានធម្មជាតិ និង បរិស្ថាន។ ប្រជាជនប្រមាណ ៦០,០០០ គ្រួសារ រស់នៅដោយពឹងផ្អែកទៅលើ ការនេសាទត្រី និង កសិដ្ឋានចិញ្ចឹមគ្រុំ។



ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានសំរេចផ្តល់ប្រាក់កម្ចី ចំនួន ១៥០ លានដុល្លាអាមេរិក ទៅនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃរាជរដ្ឋាភិបាលប្រទេសថៃ (PCD) ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ ដែលបង្ហូរចេញពីរោងចក្រ និង លំនៅឋានប្រជាជនទីក្រុងបាងកក ក្នុងនោះក៏មានខេត្តសាមុទប្រាកានផងដែរ។ ជំហានដំបូង គំរោងបានសាងសង់ស្ថានីយចំរោះពីរកន្លែង នៅដាច់ដោយឡែកពីគ្នា នៅជិតប្រភពទីតាំងរោងចក្របំពុលបរិស្ថាន ដែលមានប្រមាណ ចំនួន ៥,០០០ រោងចក្រ។ ក្រោយមក ធនាគារអភិវឌ្ឍន៍អាស៊ី បានបន្ថែមប្រាក់កម្ចីចំនួន ៨០ លានដុល្លាអាមេរិក បន្ថែមទៀត ហើយទីតាំងគំរោងត្រូវបានផ្លាស់ប្តូរទីតាំង ប្រមាណ ២០ គីឡូម៉ែត្រ ចេញពីតំបន់ក្លងដែន ដែលស្ថិតនៅចុងទិសបូព៌ានៃខេត្តសាមុទប្រាកាន។ គំរោងថ្មីបានសាងសង់ស្ថានីយ ដែលជាស្ថានីយចំរោះកាកសំណល់រាវ ដ៏ធំបំផុតនៅអាស៊ីអាគ្នេយ៍ ដែលអាចមានដំណើរការផលិតកាកសំណល់រាវ ប្រមាណ ៥២៥,០០០ ម៣ រាប់បញ្ចូលលោហធាតុរឹង និង កាកសំណល់គ្រោះថ្នាក់។ មូលនិធិសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ជប៉ុន (OECF) ក្រោយមកបានផ្លាស់ប្តូរចនាសម្ព័ន្ធទៅជា ធនាគារសហប្រតិបត្តិការអន្តរជាតិ ជប៉ុន(JBIC) ហើយថ្មីៗនេះបានកែទំរង់ជា ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ជប៉ុន (JICA) បានសហការផ្តល់ហិរញ្ញវត្ថុ ដោយបន្ថែមកម្ចីចំនួន ៥០ លានដុល្លាទៀត។ បន្ទាប់ពីប្តូរទីតាំងគំរោង ថវិកាគំរោងសរុបបានកើនឡើងទ្វេរដង រហូតទៅដល់ ៦៨៧ លានដុល្លាអាមេរិក។

អ្នកភូមិក្លងដែន បានដឹងអំពីគំរោង បន្ទាប់ពីការសាងសង់បានចាប់ផ្តើម។ នៅចុងឆ្នាំ ១៩៩៨ អ្នកភូមិបានឃើញផ្លាកសញ្ញា នៅពីមុខរោងចក្រគ្រប់គ្រងកាកសំណល់រាវ ដែលបានលើកដោយក្រុមហ៊ុនសំណង់ ជាក្រុមហ៊ុនសហប្រតិបត្តិការចំរុះ (JV)។ ពួកគាត់មានការភ្ញាក់ផ្អើលនៅពេលដែលបានដឹងថា រោងចក្រចំរោះកាកសំណល់រាវដ៏ធំសំបើម បាននឹងកំពុង

សាងសង់នៅជិតនឹងភូមិរបស់ពួកគាត់។ បន្ថែមលើការមិនបានទទួលការផ្សព្វផ្សាយព័ត៌មាន និង ធ្វើការពិគ្រោះយោបល់ពីសហគមន៍ អ្នកភូមិក្លងដែន បានបង្ហាញនូវគុណវិបត្តិធំៗដែលទាក់ទងនឹងគំរោងដូចជាៈ

១. រោងចក្រមិនបានប្រើប្រាស់ឧបករណ៍ចំរោះលោហធាតុរឹង និង កាកសំណល់គ្រោះថ្នាក់ឱ្យបានត្រឹមត្រូវ។ ពួកគេបានបង្ហូរចេញកាកសំណល់ទៅក្នុងសមុទ្រ ហើយបានបំផ្លាញដល់សកម្មភាពនេសាទរបស់អ្នកភូមិ។
២. រោងចក្រត្រូវបានសាងសង់នៅលើដីទន់នៅតាមឆ្នេរសមុទ្រ ហើយបានធ្វើឱ្យមានផលប៉ះពាល់ដោយ ទឹកជំនន់ និង ការបាក់ស្រុតដី។
៣. មិនមានការដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថាន (EIA) នៅក្នុងតំបន់ក្លងដែន។
៤. ការដ្ឋានគំរោងរួមបញ្ចូលទាំងដីសាធារណៈ ដូចជាៈ ប្រលាយទឹក ដែលច្បាប់មិនបានអនុញ្ញាត្តិឱ្យមានការទិញ-លក់។ ដីសំរាប់ស្ថានីយ មានទំហំប្រមាណ ១,៩០០រ៉ៃ (១ រ៉ៃ = ១,៦០០ ម៉ែ២) ត្រូវបានលក់ដោយតំលៃខ្ពស់ជាងតំលៃទីផ្សារ។ ម្ចាស់ដីពិតប្រាកដគឺជា អ្នកនយោបាយក្នុងស្រុក ដែលជាអ្នកនៅពីក្រោយដំណើរការ ធ្វើឱ្យមានការផ្លាស់ប្តូរទីតាំងគំរោងភ្លាមៗ។

អ្នកភូមិក្លងដែន ត្រូវបានគេជូនដំណឹងថា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គឺជាអ្នកបានកំពុងគាំទ្រគំរោងនេះ ហើយពេលនោះ ប្រទេសថៃគឺជា អ្នករៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ADB លើកទី៣៣ នៅក្នុងខេត្តឈៀងម៉ៃ ខែ ឧសភា ឆ្នាំ ២០០០។ ពួកគាត់បានសំរេចចិត្តទៅពិភាក្សាដោយផ្ទាល់ជាមួយ ADB ហើយពួកគាត់មានជំនឿថា ADB នឹងយល់ព្រមផ្អាកគំរោងដែលមានទំនាស់។ តំណាងប្រជាជនភូមិក្លងដែន ចំនួន ២០០ នាក់ បានជួបមន្ត្រីជាន់ខ្ពស់ ADB រួមមាន អនុប្រធាន និង នាយកប្រតិបត្តិពីរ-បីនាក់ នៅខេត្តឈៀងម៉ៃ។ ថ្វីបើមានការលំបាកសំរាប់អ្នកភូមិ ក្នុងការបញ្ចុះបញ្ចូល ADB ទៅលើអ្វីដែលមានជាក់ស្តែងក៏ដោយ។ ក្រោយមកទៀត នៅខែ មិថុនា ២០០០ អ្នកភូមិបានជួបពិភាក្សាជាមួយក្រុមមន្ត្រីបេសកម្ម ADB នៅតំបន់ក្លងដែន។ ចុងឆ្នាំ ២០០០ អ្នកភូមិបានចូលដល់ នាយកដ្ឋានប្រឆាំងអំពើពុករលួយ ADB។ អ្នកភូមិបានព្រមានមន្ត្រី ADB យ៉ាងខ្លាំងអំពី គំរោងដែលមានភាពមន្ទិលសង្ស័យ ប៉ុន្តែការព្រមានរបស់ពួកគេឥតបានការ។ ក្រោយមក ADB បានសំរេចបញ្ចូលគណៈកម្មការឯករាជ្យផ្សេងទៀត ធ្វើការវាយតំលៃ នៅខែ មីនា ឆ្នាំ ២០០១ ប៉ុន្តែអ្នកភូមិក្លងដែន មិនបោះបង់សេចក្តីសង្ឃឹមដែលថា ADB នឹងសារភាពកំហុសឆ្គងទាំងនោះ។



ទោះបីជាមានការតាំងចិត្តព្យាយាមគ្រប់វិធី ដើម្បីរាំងផ្ទប់គំរោងនោះក៏ដោយ ក្នុងខែ មេសា ឆ្នាំ ២០០១ អ្នកភូមិក្លូងដែន បានរៀបចំសំណុំរឿង ដាក់ពាក្យបណ្តឹងទៅការិយាល័យអធិការដ្ឋាន ធនាគារអភិវឌ្ឍន៏អាស៊ី (បច្ចុប្បន្នបានចែកចេញជាការិយាល័យពីរៈ ការិយាល័យអ្នកសំរបសំរួលគំរោងពិសេស និង ការិយាល័យគណៈកម្មការត្រួតពិនិត្យពាក្យបណ្តឹង)។ ដោយអនុវត្តតាមនីតិវិធី គណៈកម្មការត្រួតពិនិត្យ ព្យាយាមទៅកាន់តំបន់ក្លូងដែន នៅខែ តុលា ឆ្នាំ ២០០១ ដើម្បីធ្វើការស៊ើបអង្កេត ទោះបីជារាជរដ្ឋាភិបាលប្រទេសថៃ មិនផ្តល់ការអនុញ្ញាតិឱ្យគណៈកម្មការចុះត្រួតពិនិត្យនៅតំបន់គំរោងក៏ដោយ។ គណៈកម្មការត្រូវតែបញ្ចប់របាយការណ៍អង្កេត នៅខែ ធ្នូ ឆ្នាំ ២០០១ ដោយមិនបានជួបជាមួយអ្នកភូមិក្លូងដែន ប៉ុន្តែរបាយការណ៍បានចង្អុលបង្ហាញថា ADB បានរំលោភបំពានជាច្រើនចំណុចក្នុងគោលនយោបាយ និង នីតិវិធីរបស់ខ្លួន។ នេះគឺជាចំនុចសំខាន់ណាស់ ដែលជាការធ្វេសប្រហែសលើបញ្ហា របស់ធនាគារអភិវឌ្ឍន៏អាស៊ី។ ព័តិមានអាក្រក់គឺថា គណៈកម្មការ នៅតែមិនយល់ព្រមថា គំរោងនេះគួរត្រូវបានលុបចោល។ ពួកគេគ្រាន់តែផ្តល់អនុសាសន៏ ឱ្យមានការផ្លាស់ប្តូរតិចតួច ដូចជា បង់ថ្លៃសំណងគ្រប់គ្រាន់ដល់ប្រជាជនប៉ះពាល់។ អ្វីដែលជាបច្ច័យអាក្រក់គឺ គណៈគ្រប់គ្រងរបស់ ADB បានច្រានចោលសេចក្តីសន្និដ្ឋានបញ្ចប់ របស់គណៈកម្មការត្រួតពិនិត្យ និង បដិសេធដែលថា មានការរំលោភទៅលើគោលនយោបាយរបស់ ADB។ នៅថ្ងៃទី ២៥ មីនា ឆ្នាំ ២០០២ គណៈក្រុមប្រឹក្សានាយក ADB បានពិភាក្សាករណីក្លូងដែន ប៉ុន្តែបានចៀសវាងការធ្វើការសំរេចចិត្តច្បាស់លាស់ លើការរំលោភលើគោលនយោបាយរបស់ ADB។

ការផ្លាស់ប្តូរដែលបានការផ្តើមគំនិតចេញពីរាជរដ្ឋាភិបាលប្រទេសថៃ លោកនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ាត់ត្រា (Thaksin Shinawatra) ដែលទើបតែឡើងកាន់តំណែងក្នុងឆ្នាំ ២០០១ បានសន្យានឹងធ្វើការសើរើ គំរោងហេដ្ឋារចនាសម្ព័ន្ធធំៗ ដែលមានវិវាទ រាប់បញ្ចូលទាំងស្ថានីយចំរោះកាកសំណល់ក្លូងដែន ផងដែរ។ ជាការពិត លោក ថាក់ស៊ីន ក៏ធ្លាប់បានមកទស្សនកិច្ចនៅខែឧសភា ឆ្នាំ ២០០២ ហើយបាននិយាយនៅមុខអ្នកភូមិក្លូងដែន ថា "គំរោងនេះមិនមានតម្លាភាព"។ បន្ទាប់ក្រោយមក រដ្ឋបាល លោក ថាក់ស៊ីន បានបង្កើតគណៈកម្មជាច្រើន ធ្វើការសិក្សាស្រាវជ្រាវមួយចំនួន។ ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវទាំងនេះ នៅថ្ងៃទី ២៤ កុម្ភៈ ២០០៣ លោក ប្រាផាត ផានីយ៉ាឆាត្រា (Prapat Panyachartrak) ដែលក្រោយមកជា រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង ធនធានធម្មជាតិ បានបញ្ជាឱ្យផ្អាកដំណើរការសាងសង់ស្ថានីយចំរោះ ដោយពន្យល់ថា រាជរដ្ឋាភិបាលបានរកឃើញកំហុស ក្នុងកិច្ចសន្យាគំរោង។ ក្រុមហ៊ុនសហប្រតិបត្តិការចំរុះ JV មិនបានជូនដំណឹងទៅរាជរដ្ឋាភិបាលថា ក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនសហប្រតិបត្តិការទាំងនោះ ដែលមានជំនាញក្នុងការធ្វើចំរោះទឹកកខ្វក់ បានដកចេញពីសហប្រតិបត្តិការ តាំងពីមុនពេលកិច្ចសន្យាចុះហត្ថលេខា។ សហប្រតិបត្តិការ JV ខ្វះសមត្ថភាព ដើម្បីអនុវត្តន៏គំរោងនេះ ដោយគ្មានការជួយពីក្រុមហ៊ុនមួយទៀត។

បន្ទាប់មកទៀតនៅថ្ងៃទី ១៣ មករា ឆ្នាំ ២០០៤, PCD បានដាក់ពាក្យបណ្តឹង នៅតុលាការព្រហ្មទណ្ឌថៃ ចំពោះក្រុមហ៊ុនឯកជនចំនួន ១៩ និង បុគ្គលមួយចំនួន រួមបញ្ចូលទាំង លោក វ៉ាតតាណា អាសាវ៉ាហាម (Vattana

Asavahame) អតីតអនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានទទួលប្លង់ដីខុសច្បាប់លើដីតំបន់គំរោង ហើយបានលក់ដីនោះ ទៅឱ្យ PCD ក្នុងតំលៃខ្ពស់ហួសហេតុ។ ក្នុងខែ មីនា ឆ្នាំ ២០០៤ នាយកដ្ឋានដីធ្លីបានដកហូតប្លង់ដី ១,៣៥៨ រ៉ៃ។ នេះបានធ្វើឱ្យអសុពលភាពនៃកិច្ចសន្យារវាងរដ្ឋាភិបាល និង ក្រុមហ៊ុនសហប្រតិបត្តិការចំរុះ JV ។

នៅថ្ងៃទី ១៤ មិថុនា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិ ប្រឆាំងអំពើពុករលួយ ថៃ (NCCC) បានសម្រេចថាមន្ត្រីរដ្ឋាភិបាលចំនួន ៩ នាក់ រួមបញ្ចូលទាំង លោក វ៉ាតតាណា បានជាប់ពាក់ព័ន្ធនឹងការទទួលកាត់ឈ្មោះយកដីខុសច្បាប់ ហើយបានសំរេចបញ្ជូនករណីទៅផ្នែកព្រហ្មទណ្ឌតុលាការកំពូល សំរាប់កាត់ក្តីអ្នកមានតួនាទីក្នុងមុខតំណែងអ្នកនយោបាយ។ តុលាការបានគ្រោងពេលសម្រេចការកាត់សេចក្តីនៅខែ សីហា។ ប៉ុន្តែ លោក វ៉ាតតាណា បានរត់គេចពីប្រទេសថៃ ហើយមិនបានបង្ហាញមុខនៅតុលាការទេ។ ក្រោយមកតុលាការបានកាត់ក្តីថា លោក វ៉ាតតាណា មានទោសទទួលសំណូក ដណ្តើមដីដែលទាក់ទងនឹងគំរោង។ គាត់ត្រូវបានគេកាត់ទោសកំបាំងមុខ ឱ្យជាប់ពន្ធធនាគារ រយៈពេល ១០ ឆ្នាំ។

ក្នុងខែ តុលា ឆ្នាំ ២០០៩ តុលាការក្រុងឌុសិត (Dusit District) ក៏បានកំណត់ពេលចេញសាលក្រមកាត់ក្តីករណីក្លងដែន ប៉ុន្តែបានសំរេចចិត្តពន្យាពេលដល់ខែ វិច្ឆិកា ដោយសារតែ លោក វ៉ាតតាណា មិនបានបង្ហាញខ្លួនក្នុងតុលាការម្តងទៀត។ តុលាការបានចេញដីកាចាប់ខ្លួន លោក វ៉ាតតាណា នៅថ្ងៃ១២ វិច្ឆិកា ២០០៩ លោក វ៉ាតតាណា ត្រូវបានកាត់ទោសកំបាំងមុខឱ្យជាប់ពន្ធធនាគារចំនួន ៣ ឆ្នាំបន្ថែមទៀត។

បន្ទាប់ក្រោយមក កិច្ចសន្យារវាងរដ្ឋាភិបាលថៃ និង ក្រុមហ៊ុនសហប្រត្តិបត្តិការចំរុះ JV ត្រូវបានប្រកាស អស់សុពលភាពនៅខែ មីនា ២០០៣ ហើយ JBIC បានស្នើឱ្យរដ្ឋាភិបាលថៃ សងកម្ចីទាំងអស់ទៅពួកគេវិញ។ ADB នៅបន្តរដាក់របាយការណ៍ប្រចាំឆមាស អំពីគំរោងក្លងដែន បង្ហោះនៅក្នុងគេហទំព័ររបស់ខ្លួន ក្នុងគោលបំណង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តវិធានការឱ្យបានត្រឹមត្រូវ ដែលបានស្នើឡើងដោយក្រុមអធិការកិច្ច និង យល់ព្រមដោយប្រធានគណកម្មាធិការ ADB។ ADB បានឈប់បន្តរចេញរបាយការណ៍បន្ទាប់ពីឆ្នាំ ២០០៤។ គំរោងគ្រប់គ្រងកាកសំណល់រាវសាមុទប្រាកាន ត្រូវបានបិទទាំងស្រុង។

ក្នុងពេលជាមួយគ្នានេះ ស្ថានីយចំរោះទឹកស្អុយ ដែលមិនទាន់សាងសង់រួច ត្រូវបានគេទុកចោលនៅក្លងដែន។ រដ្ឋាភិបាលថៃ បានបង្ហាញការចាប់អារម្មណ៍ ស្តារគំរោងឡើងវិញ រួមបញ្ចូលទាំង គំនិតចង់តម្លើងប្រព័ន្ធនិស្សរណកម្មចំរោះទឹកស្អុយឡើងវិញ ជំនួសការបង្ហូរទឹកស្អុយ ចូលទៅក្នុងសមុទ្រ ដើម្បីជៀសវាងការប៉ះពាល់ដល់បរិស្ថាន។ អ្នកភូមិទាំងឡាយបានជំទាស់គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល ជាមួយនឹងសំណើរសុំឱ្យមានការកែប្រែជាថ្មីឡើងវិញ ដោយសំរួលមុខងារការពារបរិស្ថានសមុទ្រដល់មជ្ឈមណ្ឌលស្រាវជ្រាវ។ គ្មានគំនិតណាមួយបានលេចចេញជារូបរាងនៅឡើយ។ ពេលដែលអ្នកធ្វើដំណើរលើព្រែក (ក្លង ជាភាសាថៃ) អ្នកនឹងភ្ញាក់ផ្អើលដោយសារឃើញព្រៃកោងកាងដុះឡើងវិញយ៉ាងឆាប់រហ័ស បន្ទាប់ពីព្រៃ

ទាំងនោះត្រូវបានកាប់ឆ្ការ ដោយសារសកម្មភាពសាងសង់ស្ថានីយកន្លងមក ពេលត្រលប់មកវិញ ប្រាកដជាមិនគួរឱ្យជឿថាមានស្ថានីយគ្រប់គ្រងកាកសំណល់រាវដ៏ធំ នៅខាងស្តាំនៅដៃនៅពីក្រោយពួកវា។ ហាក់ដូចជាធម្មជាតិបានដឹងច្បាស់អំពីរបៀបរស់នៅ ដែលអ្នកភូមិក្លូងដែនចង់បាន។



អត្ថបទដោយៈ មេគង្គវ៉ច (Mekong Watch)

រូបភាពដោយៈ មជ្ឈមណ្ឌលព័ត៌មានធនាគារ (BIC) និង យូ តេ៉វ៉ាស៊ីម៉ា

ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ តូស៊ី ដ័រ តាមរយៈអ៊ីម៉ែល toshi-doi@mtd.biglobe.ne.jp

ប្រែសំរួលជាភាសាខ្មែរដោយៈ អង្គការអភិរក្ស និង អភិវឌ្ឍន៍ កម្ពុជា (CDCam)